# កិច្ចសម្ភាសរបស់ ហាន់ ផាត់

ក អ្នកសម្ភាស ថន រដ្ឋា ខ អ្នកត្រូវបានសម្ភាស ហាន់ ផាត់

កៈ បាទ! នៅថ្ងៃនេះគឺថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០២០។ ហើយខ្ញុំបាទឈ្មោះ ថន រដ្ឋា។ គឺជាក្រុមការងាររបស់គម្រោងប្រវត្តិផ្ទាល់ខ្លួនរបស់ប្រជាជនកម្ពុជា។ ហើយគម្រោងនេះត្រូវបានគាំទ្រដោយសកលវិទ្យាល័យមួយដែលមានឈ្មោះថា BYU នៅសហរដ្ឋអាមេរិច។ ហើយវេបផ្សាយគម្រោងមួយនេះមានឈ្មោះថា cambodianoralhistories.byu.edu. ហើយបើសិនជាអ្នកមីង ក៏ដូចជាកូនចៅ សាច់ញាតិអីគាត់ចង់! ចូលទៅកាន់វេបផ្សាយមួយនេះ គាត់និងឃើញការសម្ភាសដែលអ្នកមីងបានផ្តល់ដល់ខ្ញុំនៅក្នុងថ្ងៃនេះផងដែរ។ បាទ! ហើយគោលបំណងនៃការសម្ភាសនេះគឺដើម្បីរក្សានៅជីវប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកមីងទុកអោយកូនចៅជំនាន់ក្រោយបានរៀនសូត្រ និងជួយរក្សាអោយបិតថេរ និងគង់វង្សនៅជីវប្រវត្តិផ្ទាល់ខ្លួនអញ្ចឹង។ បាទ! អញ្ចឹង! ថ្ងៃនេះខ្ញុំមកជួបអ្នកមីង ហាន់ ផាត់។ អ្នកមីងមានអាយុហាសិបប្រាំឆ្នាំ។ បច្ចុប្បន្នអ្នកមីងរស់នៅក្នុងភូមិវត្តលាប សង្កាត់ចំការសំរោង ក្រុងបាត់ដំបង ខេត្តបាត់ដំបងអ្នកមីងណាំ?

ខៈ ចាស៎!

កៈ បាទ! ហើយអ្នកមីង អ្នកមីងដើម្បីអោយខ្ញុំកាន់តែច្បាស់អ្នកមីងសុំជួយប្រាប់ឈ្មោះអ្នកមីងម្តងទៀតបានទេ? ឈ្មោះអីដែរ?

ខៈ ខ្ញុំឈ្មោះ ហាន់ ផាត់។

កៈ បាទ! អ្នកមីងមានឈ្មោះហៅក្រៅទេ?

ខៈ អត់ទេអូន!

កៈ អត់ទេណាំ?

ខៈ ហ្នឹងហើយ! គេហៅថា ផាត់ៗហ្នឹងឯង។ ដល់តាដាក់ឈ្មោះ ផាត់ៗហ្នឹងឯង! ហាន់ ផាត់។

កៈ អ្នកមីងកាលនៅពីក្មេង តើអ្នកមីងមានឈ្មោះអ្វីផ្សេងទៀតទេ?

ខ៖ អត់អូន!

ក៖ អត់ទេណ៎?

ខ៖ អត់! ខ្ញុំគេហៅតែអញ្ចឹង។

ក៖ បាទ។

ខ៖ ហ្នឹង! ហាន់ ផាត់ៗ ឈ្មោះហ្នឹង។

ក៖ ចុះទាក់ទងទៅហ្នឹងអាយុ អ្នកមីងអាយុប៉ុន្មានហើយ?

ខ៖ អាយុហាប្រាំ អូន។

ក៖ អាយុហាប្រាំណ៎?

ខ៖ ហ្នឹងហើយ!

ក៖ បាទ! អញ្ចឹងអ្នកមីងមានអាយុហាសិបប្រាំឆ្នាំហើយ ប៉ុន្តែឆ្នាំខ្មែរអ្នកមីងកើតឆ្នាំអី?

ខ៖ អូនអើយ! ដឹងកើតឆ្នាំអី ខ្ញុំភ្លេចហើយកូនអើយ! ខ្ញុំមិនសូវចាំ។

ក៖ ចុះចាំខែ កើតខែអី?

ខ៖ ខែក៏អត់ដែរ។

ក៖ បាទ! ចុះថ្ងៃ កើតថ្ងៃអី?

ខ៖ ថ្ងៃក៏ភ្លេចដែរអូនអើយ! តតែមើលសំបុត្រកំណើត តែកូនទាំងអស់ក៏អត់ចាំ ខ្ញុំភ្លេច។

ក៖ ឆ្នាំខ្មែរដូចឆ្នាំ មមី មមែ វកអីអញ្ចឹងណា៎! ឆ្នាំអីគេ?

ខ៖ អរ! ឆ្នាំ ឆ្នាំវក។

ក៖ ឆ្នាំវក! ខែអីអញ្ចឹង?

ខ៖ មិនដឹងខែអី។

ក៖ ភ្លេចហើយណ៎?

ខ៖ ភ្លេច! ខ្ញុំអត់ចាំ ចាំឆ្នាំវក។

កៈ បាទ។

ខៈ ចាស៎! ចាំឆ្នាំរក។

កៈ អ្នកមីងស្រុកកំណើតរបស់អ្នកមីងនៅឯណាដែរ?

ខៈ ពីដើមខ្ញុំនៅស្វាយស៊ីសាផុនណ៎!

កៈ អរ! ស្វាយស៊ីសាផុន ខេត្ត!

ខៈ ខេត្ត!

កៈ បន្ទាយមានជ័យអី?

ខៈ បន្ទាយមានជ័យ នៅជុំម្តាយចិញ្ចឹមខ្ញុំ ម្តាយចិញ្ចឹមខ្ញុំរើសបាន! ពិបាកនិយាយវែងឆ្ងាយ។

កៈ បាទ។

ខៈ អាពតវារើស វាវៃ គាត់ទៅដឹងសសរ ដឹកអីទៅគេស្លាប់អស់ ម្តាយបង្កើតអីស្លាប់អស់អាលីង នៅតែខ្ញុំទៅ គេរត់ទាន់ ខ្ញុំឪពុកខ្ញុំហាន់ ដល់រួចទៅខ្ញុំថា ពូអើយ! ខ្ញុំសុំទៅផងម្តាយអីស្លាប់អស់ហើយកាលពីជំនាន់អាពតហ្នឹងណ៎។

កៈ បាទ។

ខៈ ក៏គេដឹកខ្ញុំទៅដល់ស្រុកភូមិដែល ភូមិស្វាយ ខេត្ត! ស្វាយស៊ីសាផុនហ្នឹង។ ដឹកខ្ញុំទៅ ក៏ខ្ញុំហើមជើង ដូច! គេអោយផឹកទឹកត្នោតមួយកែវទើបស្រកមិនដែលបានទៅលេងគេទេ! ម្តាយចិញ្ចឹម តែម្តាយបង្កើតស្លាប់អស់ហើយ គាត់ចាស់ៗហើយ ឥឡូវចាស់។

កៈ បាទ!

ខៈ ទៅ! ខ្ញុំទៅសុំគេមកកាលហ្នឹង សុំគេមកគេស្រឡាញ់ខ្ញុំគេហៅខ្ញុំ តែកូនបង្កើតសុទ្ធហ្នឹង។ ដល់ខ្ញុំមកបានប្តីខ្ញុំនៅភូមិក្បាលខ្មោចនេះ! ក្បាលខ្មោច ភូមិផ្សារជ្រៃហ្នឹង ខ្ញុំក៏មកតាមឪវា ឪវាទៅគាត់ទាញទឹកក្រិនថ្លើមស្លាប់។ ខ្ញុំអត់ដីអត់ធ្លីទៅនៅផ្លូវកាពីងពួយហ្នឹងឯង! អាងវាជិតហ្នឹងឯង។ ខ្ញុំទៅនៅ! ខ្ញុំទៅនៅទៅថា អើយ! ពិបាកណាស់ដើររកទាក់ទងអង្គការជួយសិន ជួយអី ជួយអោយបានកូនសិន កូនរៀន! ដល់បានដូចចិត្តមែន កូនបានរៀន។ មុនដំបូងមករៀនបានបួននាក់។

ក៖ បាទ!

ខ៖ ដល់នេះ! ឧស្សាហ៍ចូលទៅពេទ្យ គេដឹកដល់ពេញ មកវិញជា។ សព្វថ្ងៃហ្នឹងជាបានប្ដី បានចៅពីរហើយឥឡូវ។ កំពង់ឆ្នាំងណ៎អូនអើយ! សព្វថ្ងៃជាហើយ អរគុណគេ ហើយសព្វថ្ងៃបានរៀនពីរនាក់ ឥឡូវនៅពៅហ្នឹង! ថាពៅ អូ! ចប់លេខប្រាំពីរថា អរ! មកដល់រត់មើបម៉ែថា ម៉ែសិស្សហុកសិបនាក់ខ្ញុំចប់លេខប្រាំពីរ គេថាល្អគ្រប់គ្នាណ៎! ខ្ញុំអត់ហ៊ានយកលេខមួយទេខ្លាចគេច្រណែន ខ្លាចគេវៃខ្ញុំ ម៉ែ។ ខ្ញុំថា សំខាន់កូនកុំគិតតា អោយប្រឡងឌីផ្លូមចប់ អោយតែចប់ប្រឹងរៀនទៅ ជាពិសេសរៀន ខ្ញុំក៏ដាក់តឿន។ អូយ! អោយតែទៅរៀនអញ្ចេះអរណាស់អាអូនអើយ! ព្រោះអីយើងក្រ ចំណេះវិជ្ជាទៅ យើងបានដឹង ការងារវាធូរកម្លាំង។

ក៖ បាទ។

ខ៖ នេះ! សង្ឃឹមតែលីស៊ីម៉ង់កូនស្រីលីអីរួច! ខ្ញុំគិតអញ្ចឹង។ តែកូនប្រុសអត់កើតទេកូនអើយ! មួយទៀតជិតទៅស៊ីឈ្នួលគេ មួយទៀតធ្វើការហាងយប់។

ក៖ បាទ។

ខ៖ នេះទៅរៀនហើយ ស្រីៗពីរនាក់! សព្វថ្ងៃនៅរៀនពីរនាក់ អត់ពីរ បានគ្រួសារមួយ។ បានចៅពីរ ចៅឈឺថ្ងៃណោះ ចៅមួយទៀតទៅរៀនបាត់ហើយ ម៉ោងបួនមកវិញហើយ។ ហើយអូនអើយ! ខ្ញុំអរគុណណាស់អស់ហើយប៉ុន្នឹងកូន។

ក៖ មានសំណួរច្រើនទៀតអញ្ចឹងណ៎!

ខ៖ ចាស៎!

ក៖ បាទ! អញ្ចឹងកាលពីនៅក្មេង លឺថា! អត់មានឪពុក អត់មានម្ដាយទេ?

ខ៖ អត់ទេ! ជុំម្ដាយចិញ្ចឹមហ្នឹង។

ក៖ នៅជុំម្ដាយចិញ្ចឹម! តែកាលពីបែកបាក់ពីឪពុកម្ដាយ កាលហ្នឹងប្រហែលជាប៉ុន្មាន? ប៉ុនណ្ណា?

ខ៖ នៅតូចអូនអើយ! វៃថា ប្រាំឆ្នាំចុះ។

កៈ ប្រាំឆ្នាំអញ្ចឹង ដឹងក្តីហើយណ៎?

ខៈ ហ្នឹងហើយ! ដឹង សុំគេឡើងអាទេះហើយ គេបរអាទេះគោ គេវៃឈ្នុះអរ!

កៈ បាទ។

ខៈ ហើយនាយកអីនិយាយដូចខ្ញុំអញ្ចឹង! កាលហ្នឹងរត់ទៅអោបម្តាយ
នាយកសាលាមកប្រាប់កូនខ្ញុំ អឺ! កាលហ្នឹងម៉ែក៏សុំគេមកដៃរកូន ថា! ម៉ែអើយគ្រូខ្ញុំអោប
គ្រូនាយកខ្ញុំទៅអោបម្តាយ ម្តាយថា អត់ស្គាល់អត់មានកូនទៀត ទៅបើកខ្ទងដោះអាវខ្មោក!
ហើយយំអោបគ្នាកាលហ្នឹងដឹកគ្នា ដឹកពីកោះកាឡទៅកន្លែងនេះ ដឹកដូចខ្ញុំអញ្ចឹង!
ដឹកពីស្វាយ ដឹកពីស្វាយទៅភូមិ ដឹកតាណោះ ដឹកតាណោះ។ អ្វ!
ជំនាន់នោះកាតិកាតុបណាស់។

កៈ បាទ! គេដឹកទៅរហូត?

ខៈ រហូត! អ្នកផ្ទះដែលគេវៃដាក់ស្វាយហ្នឹងឈ្នុះ ហើយគេដឹកទៅភូមិ! គេហៅភូមិបាណយ
ចុះទៅជ្រៅ ចេះតែដឹកទៅហើយ។ ដឹកតាណោះមួយកាដុប គេបាញ់រត់គេចគ្រាប់
ហើយនៅមានគ្រាប់ទៀត រត់ដឹងខាងណាផ្លូវអូនអើយ! ទឹងៗ ល្ងាចឡើងនាំគ្នាដេកវត្ត
អាវត្តហ្នឹងចុះពីស្វាយស៊ីសាផុនហើយ ទៅអាវត្តស្អី! ហៅថា វត្តភូមិបាណយ។
ពីថ្ងៃហ្នឹងកូនខ្ញុំទៅធ្វើការខាងហ្នឹង! ទៅការដឹង ឯណា បងប្អូនអ្នកណា?
តែទៅក៏មិនស្គាល់គ្នាដែរ! ព្រោះអីខ្ញុំបានឯណោះយូរឆ្នាំហើយ។

កៈ បាទ។

ខៈ ឪវាគាត់ ទាយទឹក គ្រិនថ្លើម ទៅនៅក្នុងព្រៃពិបាកពេក ពិបាកផ្លូវចូលមករៀន។

កៈ បាទ។

ខៈ ដឹកថ្ងៃណាទៅ! វាដឹកទៅ ដឹកមកខែវង្សាភ្លៀងទៅ ផុងទៅដួលប្រឡាក់ផុកអស់
មិនបានដល់សាលាជ្រៃអរ! សាលាជ្រៃកន្លែងដើមចានៀង វារៀនហ្នឹងឯង។
បានរៀនអូនអើយ! ឥឡូវអរ សំខាន់អីអោយតែកូនចេះអក្សរទៅបានហើយ!
ខ្ញុំគ្មានអីសំខាន់អោយតែកូនចេះទេ ដូចអ្នកគ្រូសព្វថ្ងៃគេចាស់ទៅ
គេបានស៊ីប្រាក់អាត្រែត។ មិញខ្ញុំថា ពៅ! ពៅឯងរៀន រៀនអោយបានធ្វើគ្រូបង្រៀនកូន
បើរៀនអត់បានទេ រៀនមកបកអំពិល ខ្ញុំថាអញ្ចឹង។

កៈ បាទ!

ខៈ ហ្នឹងហើយអាអូន។

កៈ ទក់ទង និងអាពាហ៍ពិពាហ៍វិញម្តង អ្នកមីងមានគូរស្រករនៅអាយុប៉ុន្មានដែរ?

ខៈ ខ្ញុំអាយុម្ភៃ។

កៈ អាយុម្ភៃណាំ?

ខៈ ចាស៎!

កៈ ម្ភៃ! កាលហ្នឹង ស្វាមីរបស់អ្នកមីងឈ្មោះអីដែរ?

ខៈ ឈ្មោះ ប៊ុនធឿន។

កៈ បាទ!

ខៈ ចាស៎!

កៈ ពូកគាត់! លោកពូប៊ុនធឿន គាត់អ្នកស្រុកណាដែរ?

ខៈ គាត់ពីដើម គាត់ថា នៅបាត់ដំបងហ្នឹង! ស្រុកគាត់បាក់ចំរុំស្អីទេ! អន្លង់រូនពីកន្លែងហ្នឹង ខ្ញុំអត់ដែរមកដែរហ្នឹង។

កៈ បាទ។

ខៈ ហើយគាត់ស្លាប់នៅអាយុប៉ុន្មានទេ! សាម ឬសៃគាត់ស្លាប់ ទាយទឹក មើលអត់ជា។

កៈ បាទ!

ខៈ តែអ្នកអាមេរិចអីគេរៃលុយគ្នា មកអោយគាត់មើល តែអត់ជា។ មកពីគាត់ផឹកស្រាពីដើម ផឹកស្រាសច្រើន តែមិនជាទេជម្ងឺទាយទឹក។

កៈ បាទ!

ខៈ តែស្លាប់ហ្នឹង! កូនពៅខ្ញុំទើបបានបីខែអូនអើយ!

កៈ អរ!

ខ៖ នៅក្មេងដែរ តែឥឡូវយូរហើយ។

ក៖ បាទ! ជួយជម្រាបបន្តិចរំលឹកអនុស្សាវរីយ៍ កាលហ្នឹងស្គាល់លោកពូប៉ុន្មានឆ្នាំ? ទើបសម្រេចចិត្តយកគ្នាជាគូអញ្ចឹង?

ខ៖ អូ! អូនអើយ ពីដើមស្រឡាញ់គ្នាប្អូនដប់ឆ្នាំអីណុំ! បានជួបគ្នា។ មិនដូចឥឡូវទេ!

ក៖ បាទ!

ខ៖ ស្រឡាញ់យូរ ស្រឡាញ់ដប់ឆ្នាំ ដល់ម្ដែបានយក។

ក៖ បាទ!

ខ៖ តែខ្វះមិនបានបរបូអីទេ! នៅជុំគេ គេការអោយមួយព្រឹក។ ការមួយព្រឹកទៅ ខ្ញុំបានគ្នា គ្មានអីរកស៊ីទេ! ដំបូងអញ្ចឹងខ្ញុំនាំគាត់ដាំដំណាំអញ្ចឹង! ដាំត្រសក់ ដាំត្រសក់គាត់ថា ខ្ជិលរែកទឹក សម័យហ្នឹងរែកទឹក។ ដេល់រួចទៅគាត់មកលក់ការ៉េម លក់ការ៉េមនៅទុំទាវឯណោះ ឥឡូវខ្ញុំភ្លេចអស់ហើយ កូនអើយយូរហើយ។

ក៖ បាទ!

ខ៖ លក់ទៅចេះតែបាន ចេះតែចិញ្ចឹមទៅរហូតបាន និយាយទៅវែងឆ្ងាយណាស់អូន។ ចាប់ដីនៅកោះកាឡបាន បានគាត់។

ក៖ បាទ។

ខ៖ ចេញលើកកញ្ជើរដើររកដី ព្រោះអត់ដីកូន ដល់រួចទៅ ចេញពីកោះកាឡហ្នឹង ទៅនៅជ្រៃជុំបងថ្លៃហ្នឹង! គេថា អរ! អស់បងប្អូនហើយ ប្អូនគាត់ងាប់ គេចេញមក មកនៅអាងឈិតណោះ អាងឈិតទៅទាក់ទងអង្គការទៅបានមកនៅនេះមក។

ក៖ អរ!

ខ៖ បើមិនបានអង្គការនៅនេះឯង នៅដីរដ្ឋអូ! បានគេជូលផ្ទះអោយនៅអរ! កូនខំរៀនបន្តិចទៅមានអនាគត មានលុយសន្សំទិញដីប្អូនម៉ែត្រទៅអាអូន។

ក៖ បាទ!

ខ៖ គេដែលជួយយើងមួយជីវិតអាអូន ជឿទេ?

ក៖ បាទ។

ខ៖ គេអត់ជួយយើងមួយជីវិតទេ! ព្រោះអីខ្ញុំឃើញអង្គការនេះ ច្រើនគ្រួសារហើយ។

ក៖ បាទ!

ខ៖ បើអ្នកណាមានដី តាំងពីជំនាន់ខ្ញុំប្រជុំនៅលើឡាន ខ្ញុំប្រជុំនៅបាណន់ ភ្នំសំពៅ វត្តឯក គេដឹកទៅប្រជុំណា៎! ប្រជុំទៅគេថា បើអ្នកណាមានដី គេអាចជួយ ហើយគេជួយធ្វើផ្ទះ តេបានផ្ទះហើយ គេឈប់ចិញ្ចឹមហើយ។ គេអោយលុយបន្តិចបន្តួច យើងរកដើមធ្វើខ្លួនឯង តែបើអ្នកណាអត់ដី អត់ទាំងសប់ ទាំងគ្រប់គេអាចជូលផ្ទះអោយនៅ តែគេអត់មានទិញអោយទេ ព្រោះអីគេជួលអោយ អោយយើងរៀនចេះទៅ ប្រឹងរកខ្លួនឯងយើង។

ក៖ បាទ!

ខ៖ អស់ហើយអូនអើយ! អរគុណ។

ក៖ ទាក់ទង និងអាពាហ៍ពិពាហ៍ហ្នឹង អ្នកណាជាអ្នករៀបចំជូនអ្នកមីង?

ខ៖ ម្តាយចិញ្ចឹម ម្តាយចិញ្ចឹមទាំងសងខាង។

ក៖ អរ!

ខ៖ ម្តាយឪពុកខ្ញុំដែលឈ្មោះ ហាន់ហ្នឹង។ ហើយខាងនោះឈ្មោះ តាតក់ យាយប្រាក់ ឥឡូវគាត់ស្លាប់អស់ហើយទេដឹងមិនដែលទៅផង មិនដែលទៅ។

ក៖ ចាំឈ្មោះឪពុកម្តាយបង្កើតទេ?

ខ៖ ចាំ!

ក៖ គាត់ឈ្មោះអី?

ខ៖ ឈ្មោះ សាយ។ ពុកឈ្មោះ ឪពុកបង្កើតអរ?

ក៖ បាទ!

ខ៖ ឪពុកបង្កើតអត់ចាំទេអូនអើយ! ចាំតែម្តាយចិញ្ចឹម នៅតូចពេក។ នៅតូចអញ្ចឹងម្តាយ និងតគ្នា ម្តាយចិញ្ចឹមពីរ ស្លាប់មួយ នៅមួយ ម្តាយបីបាត់។ ជំនាន់អាពតខ្ញុំភ្លេចដែរ។

កៈ ម្ដាយចិញ្ចឹមទាំងបីមានឈ្មោះអីខ្លះ?

ខៈ ចាំបានតែមួយហ្នឹងឯង។

កៈ អរ!

ខៈ ចាំបានតែមួយ អាយុដឹងក្ដីប្រាំឆ្នាំសុំគេមកហ្នឹង។

កៈ បាទៗ!

ខៈ ជំនាន់អាពតខ្ញុំនៅតូចដែរ។

កៈ ចុះកាលដែលយកលោកពូជាគូហ្នឹងណាំ! តើអ្នកមីង ឬក៏អ៊ំស្រី!!!
បានយកថ្លៃបណ្ណាការពីលោកពូប៉ុន្មាន?

ខៈ អត់ផង! អាណិតគាត់ពេក ម៉ែចិញ្ចឹមខ្ញុំថា អត់យកទេ
ព្រោះអីគាត់ខាងណោះមានតែយាយ។

កៈ បាទ!

ខៈ ហើយគាត់នៅជុំម្ដាយចិញ្ចឹមទាំងអស់គ្នា។

កៈ បាទ!

ខៈ ហ្នឹងហើយ! ដល់ពេលនេះទៅខ្ញុំថា ទៅយកអញ្ចឹងទៅ អត់ដូចគ្នាទៅស្រួល
កុំអោយគេដៀលយើងណាំ! ជំនាន់ហ្នឹងអ្នកក្រគេដៀលយើង ប៉ុនក្រណាស់។
ប៉ុនខ្ញុំយកទៅ មានអី គាត់ផឹកទេ បានស្លាប់បែកគ្នាទៅ ប៉ុន្នឹងឯងអូនអើយ។

ខៈ ចាស៎!

កៈ អញ្ចឹងមូលហេតុអីបានជាអ្នកមីងសម្រេចចិត្តយកលោកពូជាគូអញ្ចឹង?

ខៈ នែ៎! ខ្ញុំមានចិត្តអញ្ចែកអាអូន ខ្ញុំថា ហ៊ឺ! ខ្លួនខ្ញុំក្រ ហើយនៅជុំម្ដាយចិញ្ចឹមទៀត។

កៈ បាទ!

ខៈ កាលណា ពេលអ្នកណាមកចង់ គាត់អោយយកអ្នកមានដូចថា
ម្ដាយចិញ្ចឹមប្រពន្ធចុងហ្នឹងអោយយកអ្នកមាន ខ្ញុំថា មិនហ៊ានស្រឡាញ់គេទេឌី ខ្ញុំក្រពេក។

កៈ បាទ!

ខៈ ទៅ! ខ្ញុំយកគាត់ហ្នឹងមានតែយាយ។

កៈ បាទ។

ខៈ ហ្នឹងហើយ! អស់ហើយអាអូនអើយ អរគុណ។

កៈ ទៀតៗ! ទាក់ទង និងលក្ខណៈត្រង់ណាដែលអ្នកមីងស្រឡាញ់លោកពូ ស្រឡាញ់លក្ខណៈត្រង់ណា?

ខៈ មុនដំបូងកាលនេះគាត់អត់ចេះផឹកទេ! ហើយការងារគាត់ជួយអូន និយាយទៅវែងឆ្ងាយណាស់។

កៈ បាទ។

ខៈ ពេលយើង គាត់អត់ទាន់បានអញ្ចឹងថា មនុស្សប្រុសអាក្រក់ៗចុះ អោយតែល្អ ក្រៗចុះ អោយតែ សុំតែចិត្ត។

កៈ បាទ។

ខៈ ចិត្តដើម្បីអី! ខ្ញុំពន្យល់ស្រីដូចគ្នាចិត្តដើម្បីអី! ចេះគិត ចេះគិតយើងហាត់នឿយអញ្ចឹង គាត់មកដល់។ កាលមិនទាន់បានខ្ញុំ គាត់មកភ្លាមគាត់ជួយរែកទឹក ពេលអត់អុសអញ្ចឹងគាត់ថា មកខ្ញុំជួយកាច់អុស ពេលខ្ញុំបោកខោអាវហាត់អញ្ចឹង។ ហ្នឹងមិនទាន់បានខ្ញុំទេ! គាត់ទៅជួយធ្វើចំការ គាត់ថា មកបងជួយបោកខោអាវអូនខ្ញុំថា បោកទៅ! កំពុងចុកដៃ កំពុងហាត់ផង ខ្ញុំដកដៃ ខ្ញុំក៏អោយគាត់។ ហើយខ្ញុំស្រឡាញ់ ខ្លះយកគ្នាអត់ចេះគិត តែប្តីខ្ញុំចេះគិតណាស់អាអូន។

កៈ បាទ!

ខៈ គាត់ចេះគិត ដល់ពេលបានហើយគាត់លីធ្យូង កាលណោះគាត់លីធ្យូងស៊ីឈ្នួលគេ ទៅវាហាត់ថា មកខ្ញុំជួយបោក ខ្ញុំជួយបោកខោអាវអីអោយហើយ រួចជួយហាលរួចហើយណា។

កៈ បាទ!

ខៈ ខ្ញុំឃើញកូនប្រសារខ្ញុំសព្វថ្ងៃមិនដែលជួយទេ គ្នាទៅធ្វើការ សរសៃខ្វីប្រើអោយទៅលីដែកគោយន្ត ខ្ញុំថា អញលែងចោលហើយ។ សព្វថ្ងៃនេះដែលខ្ញុំបានថៅ ខ្ញុំថា!

កៈ បាទ!

ខៈ អូ! ចាញ់ទាំងប្ដីអញទៀតមីអូនអើយ ប្ដីអញផឹកមែន តែគាត់ធ្វើការ។ បើគាត់ចង់ផឹកអញ្ចឹង គាត់ដុតអុសអាអូន។

កៈ បាទ!

ខៈ ដុតអុដសរួច កាលហ្នឹងទឹកអណ្ដូងស្នប សបទឹកអណ្ដូងស្នបរែកមករួច។

កៈ បាទ!

ខៈ ហើយដល់ពេលនេះទៅ គាត់ក៏កាច់អុសទុកអោយខ្ញុំហើយស្រេច គាត់ទៅទិញប៊ីចេងមួយកញ្ចប់ ត្រីមួយកន្ទុយទុកហើយស្រេច បានគាត់ប្រាប់ខ្ញុំថា ផឹក។ ខ្ញុំថា ផឹកអី ផឹកទៅ ព្រោះអីអញមានស៊ីហើយ ខ្ញុំក៏ថាអញ្ចឹង និយាយអញ្ចឹងណា។

កៈ បាទ។

ខៈ ខ្ញុំនិយាយតាមត្រង់អញ្ចឹង ខ្ញុំថា អឺ! ដល់រួចគាត់ថា អត់ចោលទេប្រពន្ធ។ គាត់ថា ហ៊ឺ! ទៅដល់ណា ពីរបីយប់អញ្ចឹង ដឹងបានអីស៊ីទេ! កាលហ្នឹងស៊ីឈ្នួលគេ យើងក្រណាកូន។

កៈ បាទ!

ខៈ ហ៊ឺ!  បានអីស៊ីទេ គាត់បានលុយ ដឹងគាត់បានប៉ុន្មានគាត់លាតលុយអស់អាលីងអាអូន។

កៈ បាទ។

ខៈ គាត់អស់! ហើយនិយាយទៅកាត់គេ កាត់ខ្មាស គាត់ប្រាប់អស់ពីចិត្តមនុស្សគាត់ត្រង់ គាត់ថា ហ៊ឺ! ឪអាផល ឈ្មោះ ផាត។ លែងក្បត់ចិត្តប្រពន្ធ ទៅលែងតែស្រី ឯងឈរយាមឡាន។ គាត់ថា គេទិញស្រោមអនាម័យអោយ គាត់ថា អញអត់លែងទេ អញស្មោះតែមួយ និងមួយរហូតដល់ថ្ងៃស្លាប់។

កៈ បាទ!

ខ៖ មានអាស្លាប់ហើយ គាត់ផ្តាំកុំអោយយកប្តី មនុស្សស្រីពិបាកណាស់ប្រុសផឹករាល់ថ្ងៃ។ កាលណោះអត់សូវផឹកទេអូនពីដើម។

ក៖ បាទ!

ខ៖ ពីដើមអត់សូវផឹកទេ មិនសូវផឹកដូចក្មេងពីដើមទេអូនអើយ! ខ្ញុំអរគុណអូនឯងហើយដែរបានមកសម្ភាសអូន។

ក៖ បាទ។

ខ៖ ហ្នឹងហើយ!

ក៖ ជម្រាបសួរទៀត មានសំណួរ! អញ្ចឹងកូនសរុបទាំងអស់មានប៉ុន្មាននាក់?

ខ៖ កូនប្រាំនាក់អូន។

ក៖ ប្រុសប៉ុន្មាន? ស្រីប៉ុន្មាន?

ខ៖ កូននេ៎! ប្រុសពីរ ស្រីបី។

ក៖ បាទ!

ខ៖បងគេស្រី។ បងគេស្រីហើយ បន្ទាប់មកប្រុស។

ក៖ បាទ!

ខ៖ ប្រុសបន្ទាប់បងហើយ ប្រុស។

ក៖ បាទ!

ខ៖ ហើយដល់ប្រុស ស្រីឈ្មោះទី ទេ ទិន ទូ ព្រឹក កូនប្រាំហ្នឹងឯង។

ក៖ ឈ្មោះឡូយទៀត?

ខ៖ ទិន ទូ ទី ទេប សព្វថ្ងៃទី ទេបរៀន។ ទិន ទូធ្វើការ ប៉ុន!

ក៖ បាទ!

គ៖ ចុះពុកខ្ញុំអរ!

ខ៖ អរ! ពុកកូនឯងជាកូនប្រសារ។

ក៖ ហើយកូនប្រសារឈ្មោះអី?

ខ៖ កូនប្រសារឈ្មោះ រិន។

ក៖ អរ! អញ្ចឹងប៉ាម៉ាក់គាត់ ឈ្មោះអីអ្នកមីង?

ខ៖ កូនប្រសារឈ្មោះ រិន។ កូនបង្កើតឈ្មោះ ព្រឹក ឈ្មោះបញ្ជីជាតិហៅ សុគា។

ក៖ បាទ!

ខ៖ កើតថ្ងៃអង្គារ ដាក់ឈ្មោះ សុគាអូនអើយ។

ក៖ បាទៗ! អញ្ចឹងពួកគាត់ទាំងពីរប្រកបមុខរបរអីដែរ?

ខ៖ គាត់ធ្វើស្រែ នៅតែស្រុកហ្នឹង ធ្វើតែស្រែទេកូន។

ក៖ បាទៗ!

ខ៖ ដល់ខែអញ្ចេកដឹងធ្វើអីទេ? មើលទៅអ្នកស្រែចូលចិត្តតែផឹក ខ្ញុំស្អប់តែផឹកកូនណា៎! ឈ្លោះតែគ្នាដឹងធ្វើមិច។

ក៖  បាទ។

ខ៖ ធ្វើស្រែ បើសិនគេអ្នកឧស្សាហ៍ខែប្រាំង ស្រែប្រាំងគេមានជាតិទឹកប្រឡាយ ឧស្សាហ៍ទៅលេងដែរ តែឥឡូវគេជិះឡាន អូ! ឆ្ងាយខ្ញុំខ្ជិលទៅ ឯណាចៅធ្លាប់រៀន។

ក៖ ចុះអ្នកមីងមានបងប្អូនប៉ុន្មាននាក់?

ខ៖ ខ្ញុំអរ?

ក៖ បាទ។

ខ៖ ខ្ញុំបងគេ បងប្អូនខ្ញុំប្រាំនាក់ ប៉ុនស្លាប់ជំនាន់ពពតអស់ហើយអូនអើយ! កាលហ្នឹងចាញ់ដាច់បាយ ដាច់ទឹកនៅតែខ្ញុំ ហើយបងគេ។

ក៖ ជួយជម្រាបឈ្មោះពួកគាត់បានទេ?

ខ៖ អរ! ខ្ញុំភ្លេចភ្លាំងអស់ហើយអូនអើយ! ហើយខ្ញុំឈឺ ឈឺពីអាពតសន្លប់ និងម្ដាយចិញ្ចឹមខ្ញុំយកទៅដាក់ អោយម៉ែខ្ញុំដែលមិនទាន់បានស្លាប់។

ក៖ ដឹងតែប្រាំនាក់ណា៎?

ខ៖ ចាស៎! ដឹងតែប្រាំនាក់។

ក៖ ហើយចាំបានប្រវត្តិ ដែលធ្លាប់លំបាកជាមួយគ្នាទេកាលហ្នឹង? ធ្លាប់ទៅណាខ្លះ?

ខ៖  អត់ទេ! កាលណោះពិបាកតែជំនាន់អាពតទេ។

ក៖ បាទ! ជំនាន់អាពតហ្នឹង?

ខ៖ បែកគ្នា។

ក៖ ធ្លាប់ដើរជាមួយគ្នាមិចៗ?

ខ៖ អត់បានដើរទេ! កូនឈឺដូចថា ដេកកន្ទេល ដាច់បាយ ដាច់ទឹក។ អាណាចាញ់ព្រៃផង អាណាអាពតជម្លៀសដាក់តាណោះ ដាក់តាណោះ ហើយខ្ញុំនៅតូចដែរ។

ក៖ អរ!

ខ៖ ខ្ញុំនៅជាមួយបង និងប្អូន ហើយពិសេសអាបែកបាក់គ្នា រត់! ខ្ញុំស្រណោះណាស់ ខ្ញុំថា អត់រស់ទេ! អង្គុយមុខថ្នលម៉ោងបីល្ងាចឡើង ហើយខ្ញុំក៏ប្រាប់ ឪពុកចិញ្ចឹមខ្ញុំហ្នឹងថា បើខ្ញុំពុកឯងមិនទៅយកខ្ញុំ ខ្ញុំមិនដឹងពឹងអ្វីទេ! ថ្ងៃកាន់តែលិចរ៉េៗ ខ្ញុំហើមជើងណោះ ហើមជើងឡាំងធំៗអូនអើយ! ខ្ញុំថា ខ្ញុំហេវកាលអាពត វាដាច់បាយអូ!

ក៖ បាទ។

ខ៖ គេអាឡៃរត់ ខ្ញុំថា! ខ្ញុំហេវដែរហើយ គេមកដល់ គេបបរ។ ចុះជម្លៀសគេបបរប៉ិកៗ ហើយគេអោយខ្ញុំហូប ខ្ញុំក៏ហូបបានតិច។ ដល់ព្រឹកឡើងអ្នកស្រុក អ្នកស្រែហ្នឹង គេរត់ទៅមើលទាំងយប់ សរណាស់ៗកូនចិនហើយ! ខ្ញុំថា អឺ! គេរត់ទៅមើលខ្ញុំកាក្រឹក កាក្រេង ខ្ញុំអត់ដឹងអីទេឈឺឡីលឺៗហើយ។

ក៖ បាទ។

ខ៖ ឈឺដាច់បាយ ដាច់បាយអារបៀបដាច់បាយ។ ហ៊ឺ! ខ្ញុំដាច់បាយបីថ្ងៃហើយ
បើអ្នកណាមក ហើយឃើញអាទេះតែបី អាទេះបីហ្នឹង គេដឹកឈើ ដឹកសសរប៉ុនៗនេ៎!

ក៖ បាទ!

ខ៖ អាពតវាវៃ គេវៃឈ្នះ! គេវៃឈ្នះគេទៅដឹក និងនេះ នៅស្វាយស៊ីសាផុនទៅស្រុកស្រែ
បានសសរ បានធុងការ៉េម ទៅមើលផ្ទះរត់ៗ កាលហ្នឹងអ្នកណាមានគោអីរត់រៀងហើយ
ខ្ញុំនៅតូចពេក ហើយគេដឹក ហើយបន្ទាប់មកនិយាយទៅវែងឆ្ងាយទៀត។
ខ្ញុំនៅជុំគាត់ហើយ កាលហ្នឹងគេជូនចិនទៅមួយថ្នាក់ទៀត ខ្ញុំទៅលក់ដំឡូងស្ងោរ
សន្សមមួយចង្កាក់យាយលក់តែដប់បាតផ្លូវទៅផ្ទះ ប៉ោយប៉ែតយើងទៅថៃហ្នឹង។

ក៖ បាទ។

ខ៖ ខ្ញុំទៅថៃអង្គុយលក់ម្ដាយចិញ្ចឹមខ្ញុំស្ងោរ កាលហ្នឹងគេអត់ទាន់អោយធ្វើទេខ្លះដល់ធ្វើស្រែ
ច្រូតស្រូវ ច្រូតសង្វៃ ច្រូតសង្វៃយកមកបុកហាល អត់ទាន់មានស្រែអូន!
កំពុងរត់ពេកមានអ្នកណាធ្វើស្រែ។

ក៖ បាទ។

ខ៖ ទៅខ្ញុំទៅលក់ដំឡូង ម្ដាយចិញ្ចឹមខ្ញុំដូរមាសអង្ករហ្នឹង
កាលហ្នឹងមួយគីឡូប្រាំពាន់ហ៊ុនអីចេះតែដូរទៅ ខ្ញុំទៅលក់។

ក៖ បាទ។

ខ៖ ដល់ព្រឹកៗអូ! វេទនាដែរនៅជុំម្ដាយចិញ្ចឹម ប៉ុនរួចទៅ
គាត់បានមួយក្រោលយកមកចិញ្ចឹម។

ក៖ អរ!

ខ៖ គៀនគោ គេចោល បានខ្ញុំចិញ្ចឹមគោទៅ! ខ្ញុំហេតុតែស្រឡាញ់ប្ដីខ្ញុំគាត់ថា
ចែកគោមួយអោយអ្នកផ្សេង ហើយខ្ញុំ ម្ដាយខ្ញុំក៏ចិញ្ចឹមពីតូចគាត់ថា ម៉ែអើយ!
ខ្ញុំយកគេអ្នកផ្សេងទេ ខ្ញុំអត់យកសោះខ្លាចគេអ្នកមានទៅ
យើងថាក្រណាស់អីគ្មានហ្នឹងខ្លួនណា។

ក៖ បាទ!

ខ៖ ដល់យើងអ្នកក្រចប់គ្នាសព្វថ្ងៃ អរគុណអូនអើយ! គ្រាន់បើហើយអូនឯងរៀនចេះអញ្ចឹង។

ក៖ អញ្ចឹង! ខ្ញុំសុំបន្តទៀតដោយសារមានសំណួរខ្លះដែលទាក់ទង និងជីវប្រវត្តិអញ្ចឹង។

ខ៖ ចាស៎!

ក៖ ថ្វីត្បិតតែអត់ស្គាល់ឪពុកម្ដាយបង្កើត ប៉ុន្តែឪពុកម្ដាយចិញ្ចឹមស្គាល់ណ៎?

ខ៖ ចាស៎! គាត់ចិញ្ចឹម។

ក៖ អញ្ចឹង! ស្រុកកំណើតឪពុកម្ដាយ គាត់នៅឯណាដែរ?

ខ៖ បង្កើតអី?

ក៖ ចិញ្ចឹមណា។

ខ៖ នៅស្វាយសុីសាផុនហ្នឹង។

ក៖ បាទ!

ខ៖ ស្វាយសុីសាផុន ចុះទៅភូមិឈ្មោះ ភូមិបាណយថ្មី។

ក៖ បាទ!

ខ៖ ភូមិបាណយ វត្តទឹកថ្លានៅឯបហ្នឹងឯង។

ក៖ បាទ!

ខ៖ ចាស៎!

ក៖ ចុះស្រុកកំណើតឪពុកម្ដាយបង្កើតនៅឯណា?

ខ៖ អត់ស្គាល់។

ក៖ អត់ស្គាល់ទេណ៎?

ខ៖ ចាស៎! ស្ដាយណាស់។

ក៖ មានពីណាប្រាប់ទេថា ពួកគាត់នៅណា ឯណី?

ខ៖ អត់មានអ្នកណា រត់បែកបាក់គ្នាជំនាន់ហ្នឹង។

ក៖ អរ!

ខ៖ ខ្ញុំនៅតូចពេកអូន បានខ្ញុំចាំអត់បាន។

ក៖ បាទ។

ខ៖ ហើយអាជម៉្ងឺឈឺហើម ហើមតែជើងអូនអើយ! លើកជើងខ្លួនឯងអត់រួច។

ក៖ កាលហ្នឹងអត់មានថ្នាំពេទ្យ ថ្នាំអីទេណ៎?

ខ៖ អត់ទេអូន! ជំនាន់ហ្នឹង ជំនាន់អាពត។ ហើយគ្មានដឹងអីទេ ម្ដាយចិញ្ចឹមខ្ញុំយកខ្ញុំទៅកប ហើយខ្ញុំហៅម៉ែ គាត់ទៅលើកពរវិញ។

ក៖ អរ!

ខ៖ ហ្នឹងហើយ! ខ្ញុំអត់ដឹងអីទេ ខ្ញុំបាត់ការចងចាំប៉ុន្នឹង។

ក៖ បាត់ការចងចាំ! ប៉ុន្តែគ្រាន់តែ ដឹងថាមានបងប្អូនប្រាំនាក់ ហើយអត់ដឹងថាទៅណាទៅណីទៀត។

ខ៖ ដឹងតែស្លាប់ តែខ្ញុំឆ្ងល់អញ្ចេះ! បងប្អូនខ្ញុំមានប្រាំនាក់
ខ្ញុំទៅថៃម្ដាយខ្ញុំដែលបង្កើតមុនដំបូងហ្នឹង គាត់ដេកពេទ្យ។

ក៖ បាទ។

ខ៖ ដេកពេទ្យហ្នឹង! មិនដឹងពេទ្យណាទេ គេអោយថ្នាំអីទេ
កាលហ្នឹងដូចអាចមិទន្សាយអញ្ចឹង ពេទ្យអោយលេបខ្មៅៗបានទៅដេក។ ម្ដាយខ្ញុំស្លាប់ ខ្ញុំស្មានតែដេកលក់ ខ្ញុំទៅដាស់គាត់ថា ម៉ែក្រោកឡើង
តតែស្ពុយបានខ្ញុំប្រាប់គេយកគាត់ទៅកប។

ក៖ បាទ។

ខ៖ ខ្ញុំអត់ដឹង! ហើយឪពុកខ្ញុំក៏ស្លាប់មុនម្ដាយខ្ញុំទៅទៀត ពីជំនាន់ពីសង្គមចាស់។

ក៖ បាទៗ!

ខ៖ ហ្នឹងហើយ!

ក៖ ហើយចុះទាក់ទង និងសាច់ញាតិដែលរស់នៅក្រៅប្រទេសមានទេ?

ខ៖ អត់ទេអូន!

ក៖ អត់មានទេណ៎?

ខ៖ មាន! មានខាងឪវា ខាងឪវាហ្នឹង ដឹងយ៉ាងមិចទេគេថា
ចិញ្ចឹមកាលហ្នឹងខ្ញុំកូនសរសៃខ្ចីកូនពៅខ្ញុំ គេជួយបានមួយឆ្នាំកន្លះដែរ។

ក៖ បាទ!

ខ៖ រួចចិញ្ចឹមមួយឆ្នាំកន្លះ គេទាក់ទងអង្គការស៊ីភីហ្នឹងអោយ។

ក៖ អរ! នៅប្រទេសណា? គាត់នៅប្រទេសណា?

ខ៖ គាត់នៅប្រទេសអាមេរិច។

ក៖ ស្គាល់ឈ្មោះគាត់ទេ?

ខ៖ ឈ្មោះ ភៀន។

ក៖ អរ! គាត់មានកូនចៅនៅទីនោះណ៎?

ខ៖ ហ្នឹងហើយ! ដឹងកូនគាត់ប៉ុន្មាន? គាត់បានប្ដីជនជាតិគេ គាត់អត់ដែលមកស្រុកខ្មែរផង។
ឈ្មោះ ភៀងហ្នឹងក៏ចិត្តបានដែរ ប្អូនងាប់លីថា ស្រែកយំ ស្រែកអីអោយឃើញ
មិនជាទេរោគហ្នឹង។ តែសព្វថ្ងៃលីខ្ញុំទៅលេង ភូមិក្បាលខ្មោច ផ្សារជ្រៃ និងបងថ្លៃខ្ញុំ កាលភ្ជុំ
កាលអីឆ្នាំតាមិញ ចូលឆ្នាំអី! ខ្ញុំថា មិនអីទេ ប្អូនគាត់ហ្នឹងនៅតែអាយុ នៅតែវែង។

ក៖ បាទ! គាត់សុខសប្បាយណ៎?

ខ៖ ហ្នឹងហើយ! បងផង ប្អូនផងស្លាប់ហើយ។

ក៖ បាទ!

ខ៖ ហ្នឹងហើយ!

កៈ អរគុណ។ ទាក់ទង និងមួយទៀតប្រវត្តិពីក្មេងបាននិយាយប្រាប់ច្រើនមកហើយ ចុះសុខភាពរបស់អ្នកមីងមិចដែរ?

ខៈ សព្វថ្ងៃមានជម្ងឺដែរអូនអើយ! ជាពិសេសជម្ងឺ ឫសដូងបាត។

កៈ អរ!

ខៈ ជម្ងឺឫសដូងបាតអូនអើយ! ខ្ញុំចេះតែប្រឹងទៅ ផឹកថ្នាំខ្មែរអី ថ្ងៃមុនម៉ែមីនេះ ទិញអោយថ្នាំស្អីមួយឈុតបោះគេ។ មួយឈុតបោះគេហ្នឹងប៉ុន្មានទេ! ពីរយហាសិបបាត ដឹងប៉ុន្មានទេ ដឹងលុយបាត ដឹងលុយដុល្លាទេ។

កៈ បាទ!

ខៈ លេបៗទៅអូនអើយ! ខំលេបទៀត វាធ្វើទុក លុយដុល្លាពីមុន! ពីរយហាសិបដុល្លា។

កៈ បាទ!

ខៈ លាបហើយធ្វើទុកណាស់ កាលហ្នឹងចូលទៀត! ទៅលក់ម្ជូរនៅវត្ត វត្តខ្វែង វត្តអន្លង់វិល។

កៈ បាទ។

ខៈ ចេញពីព្រឹកអញ្ចេះ ចូលវត្តខ្វែង ដល់យប់បានអន្លង់វិលណាំ។

កៈ បាទ។

ខៈ ប៉ុនលក់អត់សូវដាច់ទេអូនអើយ! កូនអើយឆ្នាំនេះ ដល់ទៅលក់ថ្នាំនេះធ្វើទុកអញ រកតែក្អួត អញវិលមុខ គេថាថ្នាំជាធ្វើទុកដេញរោគ។

កៈ បាទ!

ខៈ ឥឡូវជាដាច់ហើយ លេបជាដាច់។

កៈ អរ! លេបអស់ហើយណ៎?

ខៈ លេបអស់ហើយ លេបពីរខែថ្នាំហ្នឹង។ លេបអស់ហើយ ជាដាច់ទៀត ពេលយើងបត់ជើងទៅ យើងឈឺគូទ និងមានតែរោគមួយសំខាន់ជាងគេ

ក្រពះអីឈឺបន្តិចបន្តួច ឈឺហ្នឹងដល់យើងហូបអីដាក់តមម្ទេស
ទាំងដាក់ម្ទេសក្រពះយើងរលាកណា។

ក៖ បាទ!

ខ៖ នេះក្រពះទៅថតរួចហើយ ថតកាលពេទ្យការេថតអោយ។

ក៖ បាទ។

ខ៖ អាលាកក្រពះហ្នឹង ដល់យើងដាក់នេះទៅ ដាក់ម្ទេសទៅឈឺ
ហើយបើយើងលេបថ្នាំទៅអត់អីទេ ជាសព្វថ្ងៃឫសដូង។

ក៖ បាទៗ!

ខ៖ តែខ្ញុំព្យាបាលអត់ជាទេ!អស់ហើយថា ខ្ញុំរកថ្នាំខ្មែរ នោះ!
គេទិញអោយពីរកញ្ចប់ចេះតែរង្វល់ដាំស្ល។

ក៖ ឈឺមួយហ្នឹងណ៎?

ខ៖ ចាស៎! ឈឺតែមួយហ្នឹងទេ សព្វថ្ងៃអូន។ ព្រោះអីឈឺអីបន្តិចបន្តួច កើតខ្យល់អីបន្តិចបន្តួច
កោសបាត់ហើយ។

ក៖ បាទ។

ខ៖ ចាស៎!

ក៖ អញ្ចឹងបើសិនជាអាចព្យាបាលមួយហ្នឹងជាបាន គឺអត់សូវមានជម្ងឺអីទេណ៎?

ខ៖ ហ្នឹងហើយអូន! បើយើងព្យាបាលមួយហ្នឹងជាបាន។

ក៖ ធូរហើយណ៎?

ខ៖ ធូរហើយ ជាហើយ។ អរ! ហ្នឹងហើយ យើងចាស់ហើយស្រវាំងភ្នែក
ខ្ញុំពាក់វ៉ែនតាតាំងពីអាយុសាមសិប។

ក៖ អរ!

ខ៖ កាលពីនៅព្រិល គេសួរថា
ពេលទៅលេងកំពង់ចាមខ្ញុំធ្លាប់តែពាក់វ៉ែនតាអត់មើលអីច្បាស់អញ្ចេះ ដល់ពេទ្យគេថា
មកពីរោគឫសដូងបាតហ្នឹង! បានយើងស្រវាំងភ្នែក។

ក៖ បាទ! ហើយវិលមុខអីអញ្ចឹងណ៎?

ខ៖ ចាស៎! ដល់ពេលនេះទៅ គេសើចខ្ញុំភ្នែកបួន ភ្នែកបួនអាណាសើចអី សើចទៅ។
ក្រោមដើមស្វាយអញ្ចឹងខ្ញុំទាញវ៉ែនតាមកគឺប អាណាលឿនខ្ញុំចោលហើយ។
ត្រលាប់ទៅលក់ក៏ដូចគ្នាដែរ។ គេដាក់មុខងារថា
បើទៅទិញម្ហូរឃើញយាយនោះពាក្យវ៉ែនតាចាំទិញ។ បើអត់ពាក់វ៉ែនតាអត់ទិញទេណាស់។
អញ្ចឹងខ្ញុំសើច។ ចុះបើថ្ងៃណាខ្ញុំអត់ពាក់វ៉ែនតាទៅធ្វើមេច? ថាអញ្ចឹងអូរ។

ក៖ បច្ចុប្បន្ននេះតើអ្នកមីងប្រកបមុខរបរធ្វើអ្វីដែរ?

ខ៖ ខ្ញុំពីដើមអង្គការអោយលក់នំ នេះអាទេះនេះ។ នំដូណាត់។
តែនំនោះឈ្មោះនំដូណាត់។ឆ្ងាញ់ដាក់ទឹកដោះគោចេកពងមាន់បើសិនបើខ្ញុំ
ខ្ញុំហៅនំពោះវៀនជ្រូក។ ឆ្អិនហើយគេយកមកហាន់ហើយគេដាក់ចេកក្នុង។
តែឥឡូវឈប់លក់ហើយ។ មកលក់ម្ហូរនេះ ព្រឹកឡើងទៅលក់ហើយ។
ប៉ុន្តែបានអង្គការនេះគេអោយប្រាក់ខែដែរមួយរយសាមសព្វថ្ងៃ។

ក៖ ហេតុអីបានឈប់លក់នំដូណាត់?

ខ៖ ពិបាករុញអាទេះចេញចូលនៅឯនោះ លក់នៅពេទ្យថ្មី សាលានោះ។
សាលាមើលសាលាជាស៊ីម សាលានេតយ៉ុង ហើយលក់មិនសូវដាច់។ ឈប់លក់ទៅអូន។
ខ្ញុំមកលក់នៅទីនេះរ៉ែក់ៗទៅ មើលចៅមើលអីផងណាស់។ ដាំដំណាំដាំអីទៅ។

ក៖ លក់ម្ហូរដាច់ទេ?

ខ៖ ដាច់តើអូន។ តែថ្ងៃណាបុណ្យទានរួចអីអញ្ចឹង ដូចថ្ងៃចូលឆ្នាំចិន
បើឥឡូវអត់ដាច់ទេអូន។ មានបុណ្យមានទានលក់ដាច់ណាស់។ ម៉ាថាសទៅ
ថ្ងៃណាលក់ដាច់ទៅ មាក្រឡទៅដាក់អាយេងអាយោងទៅដប់ម៉ឺនថ្ងៃណាដាច់ទៅ។
ថ្ងៃណាបួនម៉ឺនប្រាំម៉ឺន។

ក៖ បាទ។

ខ៖ ព្រឹកមិញលក់បានបួនម៉ឺនជាង។ បួនម៉ឺនប្រាំពាន់។ ដើរចេះតែលក់ទៅអូន ជាជាង។

ក៖ លក់តែព្រឹកៗទេណ៎?

ខ៖ លក់តែព្រឹកៗទេ។

ក៖ អូរ! លក់ដាច់ណាស់។

ខ៖ លក់ដាច់បួនម៉ឺនប្រាំម៉ឺនឆ្នាំតែមិញ ទើបតែអត់ដាច់ឆ្នាំនេះទេណាស់។
ឆ្នាំតែមិញលក់ដាច់ណាស់អូន។ ស្វាយចិត ស្វាយខ្ចីល់កមកដប់គីឡូអស់។ ដប់គីឡូរិល
ដប់គីឡូអស់។ ណាហ្នឹងម្នាក់ដប់គីឡូ។ ម៉ាមុខដប់គីឡូរអស់។
ត្រាំបីបួនប្រាំគីឡូទៀតអស់បានដប់ម៉ឺនតែឆ្នាំនេះអត់អស់ទេ។
លក់តិចមានតែខ្ញុំទេគ្រប់គ្នាសល់ពេញៗរៀបដូចតាំងពិពណ៌។

ក៖ អូរ! អត់សូវមានអ្នកទិញណ៎។

ខ៖ មានតែខ្ញុំទេស្ដែ អត់មានអ្នកដាំទេថោកណាស់។
មិញនេះខ្ញុំដាំខាត់ណាដាក់ជុងទៀតហើយ ដកចេញហើយណាស់។
លក់ទៅមួយគីឡូប្រាំពាន់ បីពាន់ ពីរពាន់លក់ទាល់តែអស់។
ហើយមានបុរសម្នាក់គ្រូបង្រៀន។
អោយគ្រូបង្រៀនទាល់តែទិញបន្លែយកទៅពិសោធន៍នឹងម៉ាស៊ីណាអូន។
គេថាបន្លែនេះបើសិនគេយកទៅដាក់កិន។ បើជាតគីមីគេឈប់មកទិញហើយ។
តែគ្រូបង្រៀនថាឥឡូវចង់ដឹងយកម៉ាស៊ីនមើល។ ដល់ដាក់ម៉ាស៊ីនទៅ
គេថាម៉ាស៊ីននោះនៅស្ងៀម អូរ! បន្លែនេះធម្មជាតហើយ។ ស្រែកគេថាបើស្រែទៀតគីមី។
ខ្ញុំអង្គុយសើចអ្នកគ្រូអត់ស្លាត់ឈឹងហើយសួរឆ្ងាញ់ណាស់។
ថាស្លរឆ្ងាញណាស់ដល់ពេលដាំម្សារទៀត ទិញទៀតគ្រូបង្រៀន គ្រូពេទ្យមកទិញនឹងនេះ។
ដាំលក់រិកៗទៅ ហើយបើដាំ ខាងក្រោយខាងនេះលក់បានច្រើនម៉ឺនណាស់អូនហើយ។

ក៖ មកដល់នេះណ៎?

ខ៖ អានេះម្លប់ខ្នុរទំព្រឹកមិញលក់មួយកំណាត់ថៅឃ្លាន។ ដើមនេះក៏បេះលក់ដែរ។
ហាត់ណាស់អូនអើយព្រឹកឡើងមកបកលក់អំពិល។ នេះថ្ងៃនេះទិញបាយគេផង
បាយមួយពាន់សម្លរពីរពាន់ត្រី មានត្រីឆ្អើត្រីអីមានទាន់ធ្វើអី? ចាំធ្វើល្ងាចគេមកជុំគ្នាទៅ។
ស្លរម្ជូរព្រលិតត្រីឆ្អើអាំងត្រីនោះឯងទៅ។ ស្អុយអស់ហើយមិនដឹងឡៃតែនិយាយ។

កៈ អត់អីទេបន្តិចទៀត។ អញ្ចឹងនៅបន្តិចទៀត។ សព្វថ្ងៃ នឹងពីមុនសម្រាប់អ្នកមីងផ្ទាល់ តើអ្នកមីងគឹតថាជីវភាពពីមុន និងឥលូវខុសគ្នាទេ?

ខៈ ខុសគ្នាអូនឥឡូវដូចស្រណុកជាង។ ពីដើមអូនអើយខ្ញុំនៅបេះត្រកួនដ ដកព្រលិត ក្រអៅឈូកកណ្ដាលបឹងទៅដាក់ហើយកូនខ្ញុំអាប្រុសមួយឈ្មោះតួរទីនទៅដាក់ម៉ោងណាស់។ ទៅដាក់ម៉ោងទៅគាត់ខ្លាចទឹក។
គាត់អោយខ្ញុំទៅដើយាមរ៉េបៗមាត់ស្ទឹងខ្ញុំខ្លាចឈ្លើងខ្លាចអីយប់ព្រលុប
យប់ឡើងមកផ្សារជ្រៃ ផ្សារជ្រៃក្បាលខ្មោចនេះស្គាលដែរ?

កៈ ស្គាល់។

ខៈ ហ្នឹងហើយទូលមកលក់នឹងហើយ។
កូនខ្ញុំរៀនរត់តាមប៉ះត្រង់ណាខ្ញុំដេកពីក្បាលល្ងាចឈរឆ្អែតអញ្ចឹងម៉ោងមួយយប់ខ្ញុំនាំកូនខ្ញុំដើរកាត់។ ដល់អ្នករាយសន្ទួចថាអើយយាយផាត់អើយកូនរត់តាមណោះស្រាតននោល។
ខ្ញុំក៏បកទៅយកកូនវិញកាលណោះ។ ឡើងវេទធានា។
ឥលូវខ្ញុំស្រួលម៉ោងភ្លឺចាំអីភ្លឺបានខ្ញុំទៅលក់។
កាលពីដើមវេទនាណាស់អូនអើយក្ររកតែអង្ករហូបចិញ្ចឹមកូនប្រាំនាក់អត់រួច។
ដល់អង្គការគេទៅគេសួរដូចអូនឯងសួរអញ្ចឹង។

កៈ បាទ។

ខៈ ខ្ញុំក៏រាយរ៉ាប់ដូចអូនឯងសួរអញ្ចឹង។ អញ្ចឹងខ្ញុំក៏ប្រាប់ដូចអូនឯងសួរអញ្ចឹង។
គេគ្រាន់តែថាអូរដូចគាត់ពីបាកណាស់។ ខ្វះទាំងរៀន ខ្វះទាំងទឹក
ខ្វះសព្វគ្រប់គេក៏យកខ្ញុំមកនៅ។ ឥលូវខ្ញុំបានធូរគ្រាន់ណាស់អូន។
ធូរមែនទែនវាអត់ហាត់កំលាំងណាស់។

កៈ បាទ។

ខៈ វាហាត់ដែរតិចទូចមិនចេះ អត់ហាត់ទេប៉ុណ្ណឹងទៅរួច។
យើងដាំនេះក៏ស្ដោចទេកម៉ាស៊ីនមានអីអោយយ៉ាប់ណាអូន?
ខ្ញុំថាស្រួលទាំងអស់ខ្ញុំនៅឯណោះយ៉ាប់ណាស់។
ក្រោកម៉ោងបីម៉ោងមួយប៉ះកាលណាខ្ញុំវង្វេងនោះ។
ដឹងដៃកូនមកកូនពៅស្រែកយំអូយម៉ោងមួយយប់មកហើយ។ ស្វាត់មកដល់សុំផ្ទះគេដេក។

ដេកទៅលក់ជ្រុលថ្ងៃទៅលក់ ថ្ងៃទៅបេះវិញទៀត។
ខ្ញុំបេះតែត្រកួនលក់ទេអូនគេសម្អាសដូចអូនឯងសួរខ្ញុំអញ្ជឹងកូន។

ក៖ បាទ។

ខ៖ ហើយមកដល់គេប្រជុំថ្ងៃប៉ុន្មានខែនោះគេហៅទៅសម្អាសអញ្ជឹងដែរ។

ក៖ អូរ!

ខ៖ ហើយខ្ញុំគ្មានភ្លេចទាំងអស់ខ្ញុំឆ្លើយ។ ឆ្លើយមិនចង់ឆប់ផង។

ក៖ ឆ្លើយបានរលូនម៉ង។

ខ៖ ឆ្លើយបានខ្ញុំបេះត្រកួនពរកូន។ អាណាខ្លាចឈ្លើងផង។ ពាពិសេសខ្ញុំខ្លាចឈ្លើងផង។
តានោះគាត់ដាក់អីឈ្មោះតាលឿង។ គាត់ដាក់សាបហើយម៉ែអាឈ្លើងអូនអើយ
អូនអើយប៉ុនៗមេជើងមេដៃ។ នោះបានខ្ញុំដើរថាធ្វើមេចអោយបានមុនចុះ។
ខ្លាចដើរជាន់ឈ្លើង ឈ្លើងវាច្រើនពេកហើយ
វាពាក់ស្បែកជើងពាក់អត់កើតទេវារអិល។ដើផ្លាតខែវស្សាទឹកលូ។
ខែប្រាំងអត់សូវមានទេ។ អូឈ្លើងដល់ហើយអាអូន។ មិនដឹងមេចទេ
តែឥឡូវទៅសួរគេថាឥលូវមានឈ្លើងអត់? គេថាមានអានេះឈ្លើងកើតមកពីក្របី។

ក៖ អូរ!

ខ៖ ខ្ញខ្លាចខ្លាំងណាស់។

ក៖ បាទ។

ខ៖ សម្បូរណាស់។ តែខ្ញុំខ្លាចជាងគេអាធំអាតូចអើយ។ ខ្លាចណាស់អូនហើយនិយាយ។
ដែលក្មេងខ្លះវាអត់ស្គាល់ទេជំនាន់នេះ។
តែអញ្ជឹងដូចផ្លែងៃមុនផ្លែស្ពឺម៉ាថាសកូនខ្ញុំចៃកដាក់ទៅថត។
ថតអោយក្មេងជំនាន់ក្រោយមើលអ្នកទិញក៏ដុចមួយណាទិញដល់ជំនានក្រោយមើលផ្លែស្ពឺ
គ្មានណាស្គាល់ទេ។
គេទិញគេសុំទាំងគ្រាប់ណាអ៊្វូនដាក់មួយថាសកូនពៅខ្ញុំគេថាថតប្រហោះអោយគេមើល។
មើលស្វាយមយយចំហៀងស្ពឺមួយចំហៀងមិនដឹងថាហើយស្ពឺនោះឆ្ងាញ់ណាស់។
នរណាំទិញត្រូវហើយគេទិញ គេចាំភ្លក់ខ្ញុំលក់នឹងនោះឯង។

ថ្ងៃនេះខ្ញុំអោយគេបេះមកទៀតអត់ទេ។ ដឹងដើមប៉ុណ្ណាខ្ញុំអត់ស្គាល់ដើមផង ស្គាល់តែផ្លែ។ ស្គាល់តែផ្លែមិនដឹងដើមប៉ុណ្ណាឯណា?

ក៖ អ្នកមិងជួយជម្រាបបន្តិចទាក់ទងទៅនឹងម្ហូប។ អ្នកមីងធ្លាប់រៀនចំអិនក៏ចេះធ្វើម្ហូបអីខ្លះ?

ខ៖ ចេះធ្វើម្ហូបស្រែយើងអូន។

ក៖ មានអីខ្លះ?

ខ៖ ធម្មតាស្លរម្ជូរ ស្លរប្រហើរ ឆាស្ងោរអីហ្នឹងកូន អាំងអីហ្នឹង។
ហ្នឹងហើយបុកទឹកគ្រឿងបុកអី ប្រហុក ម៉ាម់អីនេះកូនហា ហ្នឹងហើយ។

ក៖ បាទ។ ហើយសម្រាប់អ្នកមីងផ្ទាល់អ្នកមីងចូលចិត្តពិសាម្ហូបអីជាងគេ?

ខ៖ ខ្ញុំអូនស្លរម្ជូរ បុកម្ជូរ បុកស្វាយ ត្រីអាំង ចំហុយផ្អកអីទៅណាស់។

ក៖ ស្រដៀងខ្ញុំដែរ។

ខ៖ ហ្នឹងឯង។ ម្ហូបតាអញ្ចឹងទៅជិតប្អូននេះប្អកឆ្ងាញ់។ យាយម្ជូរខ្ញុំលក់ម្ជូរ។
ខ្ញុំទិញមួយគីឡូមកយាយម្ជូរឯងទិញមួយអាទិត្យទាំងអស់ហើយមាននរណាទិញ។
ជូនកាលមួយគីឡូពីរគីឡូម៉ាអាទិត្យណាអូន។
លក់អត់ដាច់ហើយខ្ញុំអញ្ចឹងខ្ញុំមានចិត្តអាណិត។ប៉ុន្តែគេមិនអីទេគេមិនមែនអ្នកក្រទេ
ប្តីគេលក់ឡានដែរ។ ម៉ូតូឆ្វេងស្តាំដែរ
ខ្ញុំថាអូនអើយអូនលក់មិនដាច់ក៏បានលុយឡានចូលផ្ទះដែរ?
អញ្ចឹងហ្នឹងប្តីរត់ឡានហ្នឹងឯងអូន។ លក់មិនដាច់លុយឡានចូលផ្ទហាដែរអូន។
ថ្ងៃនេះមិនដាច់ថ្ងៃក្រោយគេទិញទៀតហើយ។ អើទំរាំនឹងទិញខ្ញុំផ្អក
នេះថាស្លម្ជូរព្រលិតតែត្រីឆ្អើ ស្លរម្ជូរស្វាយអាំងត្រី តែត្រីស្អុយអស់ហើយអូនមកចំ
អង្កការមកបានខ្ញុំថា អឺ! ខ្ញុំនឹកក្នុងចិត្តខ្ញុំទេណា។

ក៖ បាទ។

ខ៖ អឺ! អូនអង្គការដេដូរមនុស្សហើយតើ។ អញ្ចឹណែកខ្ញុំគឹតក្នុងចិត្តម្នាក់ឯង។

ក៖ បាទ។

ខ៖ អឺ! អូនអង្គការនេះដូចអត់ដែលមកទេណ៎?ដល់អូនឯងថាសម្ភាសទៅបានខ្ញុំដឹង។ ព្រោះអង្គការគេមកថ្ងៃមុនមកថតខ្ញុំត្រង់ហ្នឹង។។

ក៖ បាទ។

ខ៖ ត្រង់ហ្នឹង។

ក៖ បាទ។

ខ៖ កាលណោះថៅគេមិនទាន់យកអោយមើល ថាគេមកសម្ភាសសួរគ្រប់សព្វអញ្ចឹង។ ដូរអូនឯងសួរខ្ញុំអញ្ចឹងណាស់។

ក៖ បាទ។

ខ៖ ដល់រួចថា អឺ! អូនមួយនោះគាត់ពោះធំនោះថាអឺដូរមនុស្សទាំងប្តីទាំងប្រពន្ធ។ អូរអ្នកផ្សេងទេច្រឡំអង្គការដែលធ្លាប់មក។

ក៖ ទាក់អងនឹងចម្រៀងតើអ្នកមីងចូលចិត្តចម្រៀងពីដើមរឺចម្រៀងសម័យ?

ខ៖ អូរអូនហើយឥឡូវអត់ចេះស្តាប់សោះខ្ញុំ។ បើដាក់បទពីដើមកូនពៅខ្ញុំចូលចិត្តបទពីដើមដែរ។ សព្វងថ្ងៃ បង់រំលស់ទូរស័ព្ទអីក៏ដាក់បទពីដើមដែរ។

ក៖ កូនៗរបស់អ្នកមីងអាយុប៉ុន្មាន? ទាំងប្រាំនាក់?

ខ៖ អឺអូនហើយដឹងប៉ុន្មានទេនេះ? មើលក្នុងឈ្មោះនោះខ្ញុំចាំមិនបានទេអូនអើយ។

ក៖ ចុះពួកគាត់ដូចជារៀនថ្នាក់ទីប៉ុន្មានខ្លះ អ្នកនៅរៀន?

ខ៖ ពៅរៀនថ្នាក់ទីប្រាំបី។ ទីប្រាំពីរដឹង ថ្នាក់ទីប្រាំពីរ។

ក៖ នៅតូចដែរហ្នឹង។

ខ៖ ចារនៅតូចដែរ។ ប្អូនទីប្រាំពីរ។ បងថ្នាក់ទីដប់។ ទាំងប្រុសទៀតដឹងទីដប់រឺទីប្រាំបួនទេ? ទីដប់។

ក៖ បាទៗ។

ខ៖ ដឹងរៀនបានធ្វើអីទេអូនអើយមេចទេទៅមុខទៀត បើបានចេះដូចស្មើរអូនឯងក៏ខ្ញុំអរដែរកូនអើយ។ អូនឯងគ្រាន់បើហើយចេះមានអីអក្សរស្អាតសឹងអី។

ក៖ អូរ! អានេះអក្សរនៅក្នុងកុំព្យូទ័រ។

ខ៖ អញ្ចឹងអី?

ក៖ បាទ។ អញ្ចឹងទាក់ទងនឹងរឿងភាគ ធ្លាប់ចូលចិត្តរឿងអីដែរ?

ខ៖
មើលៗតែរឿងថៃទូរទស្សន៍ខូចខាតយូរហើយថាងៃណាអោយគេដាក់ទូរទស្សន៍អោយ។ រឿងថៃ ឥណ្ឌា ខ្មែរ ខ្មែរយើងក៏មើលដែរអូន។

ក៖ បាទ។

ខ៖ ខ្មែរណាសំដែងសំគាត់មើលជក់ដែរហ្នឹង។

ក៖ បាទ។

ខ៖ ទាំងរឿង បីមុខហ្នឹង មើលបើបានរឿងអត់បានដាំដំណាំទេ។ អង្គុយមើលហ្នឹង។ នេះទូរទស្សន៍ខូចអាអូនអើយ។ បើទូរទស្សន៍កុំខូចមិនបានទេ។

ក៖ បាទ។ ដោយសារចូលចិត្តសាច់រឿងណ៎?

ខ៖ មើលតែមើលផងឆ្លៀតផង។ ដាំថែមបន្តិចទៀតមិនទាន់ស្រោចផង ភ្លេចស្រោចហើយ។

ក៖ បាទ។ ទាក់ទងនឹងការងារដែលអ្នកមីងពេញចិត្តជាងគេគឺប្រភេទការងារអ្វីដែរអ្នកមីង?

ខ៖ ខ្ញុំបើតាំងពីក្មេងមក ខ្ញុំមានអារម្មណ៍ការងារខ្ញុំចូលចិត្តចំការអូន។ លក់ដូរខ្ញុំអត់សូវចូលចិត្តទេ។ ព្រោះអីចំការធ្វើអីក៏លុយដំដែរ។ ខ្ញុំធ្លាប់នៅជុំម្ដាយចិញ្ចឹមខ្ញុំគាត់ដាំមួយរដូវៗឡើងលក់នៅផ្សារស្វាយស៊ីសាផុននោះណា។ ដឹងអាកាលណោះជំនាន់អាទេះសេះយូរហើយ។ អាទេះសេះ។ ដឹកពីអាទេះសេះមកយូរហើយម៉ាគីឡូពីរគីឡូអីដដឹកមកហើយរយម៉ឺនរាប់លានដែរ។

ក៖ បាទ។

ខ៖ ថោកបំផុតសណ្ដែកតាមួយគីឡូប្រាំកាក់អីទេណាំ។ ក៏បានលុយដុំដែរខ្ញុំចូលចិត្តចំការជាងគេ តែលក់អានេះខ្ញុំធ្វើអត់រួចចាស់ហើយ អានេះចេះតែដាំបន្តិចបន្តួចណាស់។

ក៖ បាទ។

ខ៖ បើលក់ដូរខ្ញុំអត់ចង់លក់ទេ។ ខ្ញុំចង់ចំការជាងគេ ព្រោះអីចំការវាល បើយើងដាំគ្រប់ទៅ វាមានគ្រប់មុខចំការ។ ដែលខ្ញូធ្លាប់ដាំមានត្រសក សណ្ដែកខ្ញុំធ្វើតែចំការ។

ក៖ បាទ!

ខ៖ ខ្ញុំដាំតាំងពីឥឡឹកអី ធ្លាប់អស់ហើយ។ ដាំឆ្កែតឆ្អន់ហើយ អូនអើយ។ កាលហ្នឹងស្មាខ្ញុំមិនទាន់បាត់ផ្លែផង នៅស្នាមនៅឡើយ។ ស្មាខ្ញុំដោះអោយកូនមើល មើលស្មាម៉ែរែកទឹក កូនឯងមិនជឿមកមើលស្មា មានតែកូនពៅខ្ញុំទេ។

ក៖ បាទ។

ខ៖ គេខ្លាចខ្ញុំនិយាយកុហក អូ! រែកមែន។ ហើយថ្ងៃមួយទៅទិញកថាំងបានមួយជំហៀង ដើរសួរដងរែក គេសើចឯង។ គេសួរថា អូ! អ្នកមីងអើយរែកអីទៀត គេប្រើសុទ្ធតែទឹកម៉ាស៊ីន។ ខ្ញុំថា ណាំ! អាអូនខ្ញុំឃើញទឹកប្រឡាយ គេមកសុំដំណាំខ្ញុំយកទៅដាំ ដកដំណាំរួចអីទៅ ខ្ញុំឃើញគេស្រោចទឹកប្រឡាយហ្នឹង វាអត់ជាតិគីមី អត់មានម៉ាស៊ីន អត់មានបង់ថ្នាំ បង់អី។ ក៏ខ្ញុំទៅសួររកដងរែក មករែកដកពិសោធន៍។

ក៖ គេថាអោយទៅណាំ?

ខ៖ អត់មាន! រកអត់បាន ទៅសួរយាយនោះ ដងរែកខ្ញុំមាន បើចង់ទៅសួរតតែមានដងរែក រែកសាកលរមើល។

ក៖ ពេលទំនេរចូលចិត្តធ្វើអី?

ខ៖ ពេលទំនេរអាអូន! អ្នកមីងចូលចិត្តមកដល់នេះ ដាំដំណាំ។ ម្សិលមិញទំនេរដាំបានអាខ្លីៗ ដល់ទំនេរបកអំពិល បកអី។ ដាំបាយអោយចៅហើយ និងមកដាំដំណាំវិញហើយ។

ក៖ អរ!

ខ៖ នេះ! ស្ពីហាង ស្ពីតឿ អានេះផ្កាស្ពៃ។ អូនអើយ! ដាំដំណាំខ្ញុំដកពិសោធន៍សាកមើល ខ្ញុំចង់ដឹង ដីតាហ្នឹងគេថាមិនស្រួល ដាំម្លូបមិនកើតទេ។

ក៖ អរ!

ខ៖ ដំណាំដាំម្លូបអត់កើតទេ ខ្ញុំបន្តមើល ខ្ញុំចង់ដឹង មានអីខ្ញុំដាំបីរោងខូច។ ហ្នឹងដាំម្លូបអត់កើតទេ បានតែលក់ បើរបស់ផ្លែ អត់ផ្លែរលីង។

ក៖ អរ!

ខ៖ ហ្នឹងហើយ! គេអោយខ្ញុំដាំផ្កាស្ពៃ ខ្ញុំ វាអត់ផ្កាធំទេ ដោយសារខ្វះទឹក។

ក៖ ខ្វះពន្លឺ?

ខ៖ ថាដីនេះគេដាំមិនកើតទេ ឥឡូវខ្ញុំសាបអោយវាមើល ហើយវាអត់ជឿទៀត។ ថាខ្ញុំអត់ដាំទេ។

ក៖ បាទ

ខ៖ គេលក់

ក៖ បាទ។ ទាក់ទងនឹងធ្លាប់ដើរលេងបានប៉ុន្មានខេត្តពីក្មេងរហូតមកដល់ឥលូវ?

ខ៖ អូរអូនហើយពីក្មេងមិញ និយាយពីក្មេងមិញ។ ធ្វើចំការហើយមកលក់អត់ដែលដើរទេ។ ដូចមានបុណ្យចូលឆ្នាំ បុណ្យភ្ជុំបិណ្យខ្ញុំអត់មានពេលដើរលេងទេអូន។ ពេលខ្ញុំដើលេងខ្ញុំដើរលេងមួយយប់នោះខាតណាស់។ កាប់អំពៅសាងទៅម៉ៅអំពៅសាងគេពីរបាច់។ ទឹកត្នោតជូរម៉ាវែកទៅសិន។ ដាក់ហើយក្រែកលោកភ្ញៀវមកដាក់ក្នុងជញ្ជាំងខ្ញុំលក់លឿនល្មោនវាលេងរវល់មើលល្មោនខាត។ ដល់ទៅពេលកាម៉ងទឹកត្នោតជូរវែកទៅម៉ាវែកកាលណោះដុតភ្លើងចង្កៀង។ ផឹងទៅធុំតាប្រេងក៏មាន។ ព្រឹកឡើងអាំងកណ្តុរលក់។ នាក់មកពីថៃលក់ដាច់ណាស់កូនកាលហ្នឹងសុទ្ធតែលុយបាត។ ខ្ញុំលក់អំពៅសាង អោយក្មេងៗគេអត់ងងុយណា ហើយទឹកត្នោតជូរអោយអ្នកផឹក។ ខ្ញុំអត់ភ្លេចទេអត់ដែលបានដើរសោះ។ តែខ្ញុំនៅជុំម្តាយចិញ្ចឹមខ្ញុំកូនច្រើនពេក។ បងប្អូនខ្ញុំជិតម្ភៃនាក់។ ដប់ប្រាំបីនាក់ ទៅខ្ញុំបងគេនៅជាមួយគាត់។ គាត់រើសខ្ញុំមកទៅ ដល់ពេលនេះទៅខ្ញុំថា

អាណិតប្អូនៗកំពុងរៀន។ ខ្ញុំទៅរែកទឹកត្នោតដល់ថាបើតឡូវល្ហោនលែង កាលហ្នឹងសំបូរល្ហោនលេងណាស់។

ក៖ បាទ។

ខ៖ ល្ហោនលេងហើយកាលណោះខែបុណ្យចូលឆ្នាំ។ ទៅរែកទឹកត្នោតជូរសិន ទៅកាត់អំពៅ។ អំពៅសាងពីរបាច់ កាលណោះអំពៅសាង។ ទៅកាប់គល់អាសីដាច់ដៃដាច់ជើង។ អំពៅសាងអត់ថង់ទេ។

ក៖ បាទ។

ខ៖ ហើយមានតែស្លឹកឈូកនឹងស្លឹកចែកទេ អំពៅសាងកាលណោះអត់មានថង់ទេ។ ក្មេងសព្វថ្ងៃអត់ដែលមានទេ និងអត់ដែលឃើញអំពៅសាង គេសួរថាសាងមិច! សាងតឡូវមានអំពៅកង់អញ្ចឹង។ ហើយកាលមុនគល់អាសីមួយគល់មកលីធ្វើសាងវាស់ល្ងាច ម៉ោងបីចាប់ការរែកទៅ កាន់ដាក់ចង្កៀង អោយប្រេងពេញអោយហើយ។ ដាក់ទៅហើយអំពៅសាងពីបីកញ្ជើរទៅ រែកមក អត់ហានដើរអូន ខ្ញុំខ្លាចខាតការងារ។

ក៖ បាទ។

ខ៖ ខ្ញុំថា កាលណាដើរលេងមួយយប់ហ្នឹងបើលក់ ក៏បានមួយពាន់ដែរ។ ហើយកាលហ្នឹងនិយាយលុយបាតអរ!

ក៖ បាទ។

ខ៖ លក់យប់បានបី បួនពាន់បាតដែរ អំពៅសាងពីរបីបាច់វែងៗ ដើរទៅដល់ចំការ កាលហ្នឹងមួយដើមប៉ុន្មាន? មួយកាក់ ពីកាក់ទៅសិន ទៅកាប់អំពៅ ហាត់ណាស់អំពៅសាង សកផ្អែមតែខ្លួន យើងសកអញ្ចឹងផ្អែមទាំងដៃអាវ។ អង្គុយសកអំពៅសាងហ្នឹង កូនសួរ កូនពៅខ្ញុំថា ម៉ាក់ឯងអំពៅសាងខ្ញុំអត់យល់ទេ! សព្វថ្ងៃអំពៅធំ អំពៅសាងគល់អាសី។ គល់អាសី! គល់អាសីគេកាប់អាសីរាងចាក់ ហើយអាសីហ្នឹងកុំអោយមានបែក កុំអោយមានអីស៊ីយកអាសីសាឡូនបានធ្វើសាងដុតទៅស្អាត សាងវាប៉ុនៗមេជើង យកមកដល់យើងពុះតូចៗទៅយើងដោតដូចជាផ្កាអញ្ចឹង។

ក៖ បាទ។

ខ៖ ខ្ញុំថ្ងៃណាខ្ញុំទៅ ហើយខ្ញុំទិញអំពៅមួយដើម ហើយដោតអោយកូនខ្ញុំមើល។
ទិញអំពៅមួយដើម ទិញសាងហើយ សាងស្រុកស្រែណា។

ក៖ ផ្អែមអត់អញ្ចឹ?

ខ៖ ផ្អែមតា! ឆ្ងាញ់ណាស់អូន។ អំពៅអញ្ចឹង អំពៅសាង អូនឯងអត់ទាន់ដឹងដែរ!

ក៖ អំពៅសាងបានន័យថា អំពៅហ្នឹងផ្អែម ឬមិច?

ខ៖ ផ្អែមដូចយើងហ្នឹងឯង ប៉ុនដោតតាមគល់អាសី អំពៅសាង។

ក៖ អរ!

ខ៖ វាអត់មានខាំទេ ហើយស្លឹកឈើ គេចាំស៊ីមួយសារៗ ហើយស្អាតពេលកាប់កង់ៗហើយ
យើងយកមកដោត និងដើមគល់អាសីហ្នឹង។

ក៖ បាទ។

ខ៖ ដោតបានប៉ុនៗមេដៃហ្នឹង ធ្វើគល់ធំទៅសាច់តាមធំ
ហើយកាលហ្នឹងមួយសាងប្រាំកាកអី? អូ! លក់ដាច់អស់ទាស់អាអូនអើយ។

ក៖ បាទ។

ខ៖ លក់ដាក់កញ្ជើរ ហើយសាង គ្រាន់តួអាសីហ្នឹងធូន់ ចុះយើងច្រើនអរ។

ក៖ បាទ។

ខ៖ មួយគល់ទៅកាប់ហើយអូនអើយ ហាត់ណាស់ ហើយបើនិយាយរឿងហាត់ ហាត់ៗណាស់
លក់អំពៅសាងហ្នឹង។ និងកាប់គល់អាសី ទៅកាប់អំពៅ ហើយរើសអាណាផ្អែម
កាបលីមកទឹកត្នោតជូរលក់ពីរមុខហ្នឹង កណ្តុរអាំងហ្នឹងពេលបុណ្យ
បើអត់លក់ស្តាយលុយ។

ក៖ បាទ។

ខ៖ ស្តាយលុយណាស់ ហើយអង្គុយថា ទៅលក់ ទៅមើលគេផង។
អាឡៃតែលក់មានបានស្អីល្ហេនចប់រឿងអស់អាលីង ហ្នឹងឯង។
ល្ហេនចប់រឿងអស់អាលីង។

កៈ បាទ។ អញ្ចឹងចង់ជម្រាបសួរទាក់ទងផ្ទះពីដើមរបស់អ្នកមីងមានទេ?

ខៈ មាន! អូនអើយឈើពុកនៅស្រុកស្រែ នឹងព្រៃឯណោះ ផ្ទះក្តារ វាមិនមែនថ្មអី។

កៈ បាទ។

ខៈ ឈប់នៅក៏ផ្ទះពុក បាក់ហើយរើ កាលណោះលក់អោយគេចេញមកឆ្ងាយ
លក់ទៅក៏លក់ទៅបានប៉ុន្មានទេ។
បានប្រហែលដប់ម៉ឺនខ្មែរហើយកូនខ្ញុំសែលសេរសៃប្រសាទបើកចាយ។

កៈ បាទ។

ខៈ អើយ។ អូនខ្ញុំសូមទោស ខ្ញុំទៅមើលការបូបលុយអោយគេបន្តិចសិន។

កៈ បាទខ្ញុំសុំបន្តទាក់ទងទៅនឹងផ្ទះពីដើមធ្វើខ្លួនឯង ឬក៏ជួលជាង?

ខៈ ផ្ទះហ្នឹងផ្ទះរកគេកូន រកគេដូចនេះបងប្អូនខាងប្តីគាត់ធ្វើអោយនៅ
ឈើពុកសរសេរសព្វថ្ងៃរើទៅដូចថា ឈើផ្ទះឈើ ក្តាពិក ក្តាដើមរការដើមអី។

កៈ ធ្វើប៉ុន្មានថ្ងៃហើយ?

ខៈ ហឺអូនអើយធ្វើម៉ាព្រឹកហើយផ្ទះនោះខ្ទម។

កៈ បាទ។

ខៈ ផ្ទះខ្ទមតូចបើសិន គេនាក់មានគេហៅខ្ទមចាំស្រែទេណាស់។

កៈ ក្តីស្រមៃរបស់អ្នកមីងកាលនៅពីក្មេងគឹតថាធំឡើងចង់ធ្វើអីទេ?

ខៈ ខ្ញុំនោះ។

កៈ បាទ។

ខៈ អើ! ធំទៅខ្ញុំអត់មានចង់ធ្វើអីទេអូន។ ដូនអូនសួរពីមុនអញ្ចឹង
ខ្ញុំថាចង់ធ្វើចំការអញ្ចឹងណា។ ដាំអីវ៉ាន់ ចំការធំៗ ខ្ញុំចង់ធ្វើតាចំការ
ដាំដំណាំអីធំដូចជាចំការស្វាយចំការដូងចូលទៅមានត្រជាក់ល្អឹប មានអាងទឹកស្រះទឹក
អញ្ចឹងខ្ញុំចង់អញ្ចឹងវិញ។

កៈ បាទល្អ។
ខ្ញុំអរគុណអ្នកមីងដែលបានផ្ដល់ការសម្ភាសតាំងពីដើមរហូតដល់ចប់អញ្ចឹងមិននឹងបញ្ចប់ខ្ញុំចង់ជម្រាបបន្តិចថាទាក់ទងនឹងគោលបំណងនៃការសម្ភាសនេះគឺដើម្បីរក្សានៅជីវៈប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកមីងផ្ទាល់តាំងពីក្មេងមកដល់ឥឡូវនេះ។

ខៈ ដែលកូចកូនឯងនិយមុនដំបូងអញ្ចឹងណំ?

កៈ បាទ។

ខៈ ចង់ដឹងក្មេងសារក្រោយដឹងថាប្រវត្តិយើងយ៉ាប់យ៉ាងមេខ។

កៈ បាទដើម្បីអោយក្មេងៗជំនាន់ក្រោយអាចជួយរក្សា
បានន័យថាអាចស្គាល់អូរនាក់មីងសម័យនេះពិបាកមេចៗអញ្ចឹងណាស់។ ហើយជួបប្រទះហើយមានភាពងាយស្រួល ហ៎យបាន ហើយលក់អំពៅច្រកាក់ដោតមេចនឹងណាស់។
អំពៅសាង បាទអញ្ចឹងខ្ញុំសូមបញ្ចប់។ ខ្ញុំសូមបញ្ចប់ការសម្ភាសតែប៉ុនណេះ
ហើយអរគុណដល់អ្នកមីងហើយខ្ញុំជូនពរអ្នកមីងមានសុខភាពល្អ ហើយមានកំលាំង
ហើយមានប្រាជ្ញាអញ្ចឹងណាស់។

ខៈ ចាស។ អរគុណអូនើ

កៈ បាទ។ ជម្រាបលាណាំ។

ខៈ ចាស៎។ (ចប់)។